រៀបចំដោយ

រួមសហការដោយ

# សេចក្តីថ្លែងការណ៍របស់អង្គការមិនមែនរដ្ឋាភិបាលទៅកាន់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ផ្អែកលើលទ្ធផលនៃកិច្ចប្រជុំពីរថ្ងៃរបស់អង្គការសង្គមស៊ីវិលទៅលើប្រសិទ្ធភាពនៃការអភិវឌ្ឍន៍

## ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១០

អង្គការសង្គមស៊ីវិលសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងសូមថ្លែងអំណរគុណរាជរដ្ឋាភិបាល ចំពោះការបើកទូលាយឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិលទៅក្នុងដំណើរការសម្របសម្រួលជំនួយនៅកម្ពុជា ។ តំណាងនានាមកពីបណ្តាអង្គការសង្គមស៊ីវិលដែលបានជួបជុំគ្នានៅភ្នំពេញ កាលពីថ្ងៃទី ២០ និង ២១ ខែ កក្កដា ឆ្នាំ ២០១០ ដើម្បីពិភាក្សាអំពីយន្តការដែលយើងទាំងអស់គ្នាទទួលខុសត្រូវចំពោះការចូលរួមចំណែករបស់យើងទាំងអស់គ្នា ចំពោះការសំរេចបាននូវប្រសិទ្ធភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា។

អង្គការសង្គមស៊ីវិលសូមវាយតម្លៃខ្ពស់ចំពោះឱកាសចូលរួមក្នុងកិច្ចពិភាក្សារយៈពេលពីរថ្ងៃកន្លងទៅនេះ ដែលជាលទ្ធផលនៃការចូលរួមនេះ យើងខ្ញុំមានការយល់ដឹងកាន់តែស៊ីជំរៅអំពីប៉ារ៉ាម៉ែត្រ និងភាពស្មុគស្មាញនៃប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ និងការចូលរួមរបស់សង្គមស៊ីវិលទៅក្នុងការធានាប្រសិទ្ធភាពនៃការអភិវឌ្ឍន៍នៅកម្ពុជា និងការចូលរួមចំណែកទៅក្នុងយន្តការនេះថ្នាក់អន្តរជាតិ ។ យើងទាំងអស់គ្នាបានដឹងហើយអំពីសមិទ្ធិផលយ៉ាងច្រើនរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដែលបានចូលរួមចំណែកយ៉ាងច្រើនក្រាសក្រែលទៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមនៅកម្ពុជា។ យើងខ្ញុំគោរព និង ផ្តល់ការវាយតម្លៃខ្ពស់ចំពោះការដឹកនាំដំណើរការអភិវឌ្ឍន៍កម្ពុជាដោយតួអង្គជាច្រើន ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា។

តាងនាមឱ្យអង្គការសង្គមស៊ីវិល យើងខ្ញុំសូមលើកឡើងនូវចំណុចសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងតួនាទី និង បញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិល និងសារៈសំខាន់ដែល សង្គមស៊ីវិលបានដើរតួ:

- សង្គមស៊ីវិលខ្លួនឯងផ្ទាល់ ក៏ជាតួអង្គសំខាន់មួយនៅក្នុងការធានាការអភិវឌ្ឍន៍ដែលមានប្រសិទ្ធផលនៅកម្ពុជា ។ យើងទាំងអស់គ្នាបានចូលរួមចំណែកយ៉ាងសំខាន់ទៅក្នុងការអភិវឌ្ឍន៍កម្ពុជាជាពិសេសនៅក្នុងផ្នែក: ផ្តល់សេវា ការកសាងគោលនយោបាយអភិវឌ្ឍន៍ និងការស្រាវជ្រាវ ការតស៊ូមតិ និងក្នុងការសំរបសំរួលដំណើរការប្រជាធិប្បតេយ្យនៅកម្ពុជា ។ យើងខ្ញុំជួយបំពេញគម្លាតសង្គមនៅក្នុងដំណើរការអភិវឌ្ឍន៍ដែលតួអង្គផ្សេងទៀតមិនអាចធ្វើបាន ។

- អង្គការសង្គមស៊ីវិលនៅកម្ពុជាធ្វើការចំរុះ ឬស្ទើរគ្រប់វិស័យនៃការអភិវឌ្ឍន៍នៅកម្ពុជា ។ អង្គការនីមួយៗមាន ភាពខុសគ្នា ទៅតាមវិសាលភាព រចនាសម្ព័ន្ធ និង ទំហំការងារ របស់ខ្លួន ។

ភាពចំរុះគ្រប់វិស័យ នេះហើយ គឺជាភាពខ្លាំងរបស់សង្គមស៊ីវិល ។ ប្រសិទ្ធភាពរបស់យើង អាចត្រូវបានមើលឃើញថាជាលទ្ធផល នៃភាពចំរុះគ្រប់វិស័យនេះ ។

- គោលការណ៍រួមដែលអង្គការសង្គមស៊ីវិលនៅកម្ពុជាបានប្រកាន់យករួមមាន: យុត្តិធម៌សង្គម ការចូលរួមសមធម៌ (រួមមានសមធម៌យេនឌ័រ) ឯករាជ្យភាព (ជាពិសេសពីគណ:បក្សនយោបាយ) ប្រជាធិប្បតេយ្យ តម្លាភាព ការលើកកំពស់សិទ្ធិអំណាច ភាពជាដៃគូរ គុណតម្លៃដែលមានការចូលរួម ការទទួលខុសត្រូវ និងសិទ្ធ ជាដើម។

បញ្ហាប្រឈមមួយចំនួនដែលអង្គការសង្គមស៊ីវិលនៅកម្ពុជាបាន និងកំពុងជួបប្រទះរួមមាន:

- កង្វះនូវថវិកាសំរាប់ទ្រទ្រង់សកម្មភាព និងដំណើរការរយ:ពេលវែង និងនិរន្តរភាព
- ការទាមទារដែលពុំមានការសំរបសំរួលរបស់ដៃគូអភិវឌ្ឍន៍ ឧទាហរណ៍ ការទាមទារនានាពាក់ព័ន្ធនឹងការសរសេររបាយការណ៍ដ៏ស្មុគស្មាញ
- បញ្ហាលំបាកនៅក្នុងការទទួលបានព័ត៌មានដែលទាន់ពេលវេលា
- ភាពប្រឈម ក្នុងឱ្យសហគមន៍មានការចូលរួមរៀបចំគំរោងឱ្យមានភាពជាម្ចាស់
- ការសំរបសំរួលក្នុងចំនោមសង្គមស៊ីវិលនៅមានការលំបាកដោយសារភាពចំរុះនៃយើង
- កាលានុវត្តភាពក្នុងការពង្រឹងសមត្ថភាពរបស់ខ្លួន ជាពិសេសទាក់ទងនឹងការគ្រប់គ្រង អភិបាលកិច្ច នៅមិនទាន់បានទទួលទូលំទូលាយនៅឡើយ
- កង្វះការទទួលស្គាល់ ឧទាហរណ៍ ការដើរតួភាពជាតំណាងនៅក្នុងការជជែកពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍

តាមរយ:នេះ យើងខ្ញុំចង់បាននូវការទទួលស្គាល់កាន់តែច្រើនឡើងថែមទៀត ដោយរួមបញ្ចូលការទទួលបានឱកាសពង្រឹងសមត្ថភាពរបស់ខ្លួនខ្ពស់ និង សំលេងខ្លាំងក្លាជាងមុននៅក្នុងដំណើរការអភិវឌ្ឍន៍នៅកម្ពុជា។ អង្គការមិនមែនរដ្ឋាភិបាល ក៏ជាតួអង្គអភិវឌ្ឍន៍ដែលជាតួនាទី និងសិទ្ធរបស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលមានបទពិសោធន៍ដ៏មានតម្លៃរបស់ខ្លួន និងចំណេះដឹងពីកំរិតមូលដ្ឋានដែលដៃគូអភិវឌ្ឍន៍អាចពឹងផ្អែក និងប្រើប្រាស់ជាព័ត៌មានមួយដ៏មានសារ:សំខាន់សំរាប់ការធ្វើសេចក្តីសំរេចចិត្តរបស់ខ្លួនក្នុងការផ្តល់ជំនួយអភិវឌ្ឍន៍មកកម្ពុជា។ យើងខ្ញុំចង់បាននូវការធានាថា ចំណេះដឹង បទពិសោធន៍ និងជំនាញរបស់យើង ត្រូវបានទទួលស្គាល់ យ៉ាងពេញលេញដោយដៃគូអភិវឌ្ឍន៍។

អង្គការសង្គមស៊ីវិលមានទំនួលខុសត្រូវខ្ពស់ទៅលើការងាររបស់ខ្លួន ជាពិសេសគឺមានកំរិតគណនេយ្យភាពខ្ពស់។ ជាឧទាហរណ៍នៃការទទួលខុសត្រូវនេះគឺការរៀបចំនូវ ក្រមសីលធម៌ និងវិញ្ញាបនប័ត្រស្វ័គចិត្តស្តីពីអភិបាលកិច្ចល្អរបស់ អង្គការមិនមែនរដ្ឋាភិបាល ( NGO Code of Ethical Principles and Minimum

រៀបចំដោយ

រួមសហការដោយ

Standards of Good Governance)។ យើងខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់ចំពោះការគាំទ្រគ្នា ទៅវិញទៅមក (ផ្នែកបច្ចេកទេស) ដើម្បីឈានទៅសម្រេចស្តង់ដារនេះ។ អង្គការសង្គមស៊ីវិលមិនអាច និងមិនគួរត្រូវបានវិនិច្ឆ័យ ឬផ្តន្ទាទោសជារួម ឬជាទូទៅចំពោះកង្វះខាតរបស់អង្គការមួយចំនួនតូច ជាពិសេសទៅលើការគោរពតាមគោលការណ៍អភិបាលកិច្ចល្អឡើយ។

អង្គការសង្គមស៊ីវិលបានចាប់ផ្តើមនូវដំណើរការមួយដែលកំណត់ពីយន្តការនានា គោលការណ៍ណែនាំ និង សូចនាករ ដែលនឹងជួយយើងទាំងអស់គ្នាឱ្យគោរពតាមគោលការណ៍នៃប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ដែលយើងទាំងអស់គ្នាបានកំណត់។ យើងទាំងអស់គ្នាត្រូវការពេលវេលាបន្ថែមដើម្បីអនុវត្តដំណើរការនេះឱ្យបានពេញលេញ។ យើងខ្ញុំសូមឱ្យមានការប្រឹក្សាយោបល់ជាមួយដៃគូអភិវឌ្ឍន៍នៅក្នុងការសំរេចការងារនេះ និងសូមស្នើដៃគូអភិវឌ្ឍន៍គាំទ្រ និងចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះ។

តាមរយៈបញ្ហាប្រឈម និងតួនាទីដ៏មានសារៈសំខាន់ដែលត្រូវបានលើកឡើងដោយសង្ខេបខាងលើ យើងខ្ញុំសូម ស្នើដល់រាជរដ្ឋាភិបាល សូម៖

- ពង្រឹងនូវការពង្រឹងការអនុវត្តច្បាប់ ហើយការអនុវត្តក្នុងលក្ខណៈមួយដែលមានភាពស្មើភាព និងការទទួលខុសត្រូវ
- បង្កើន និងផ្តល់នូវការពិភាក្សាកាន់តែមានលក្ខណៈជាប្រព័ន្ធ និងមានសារៈសំខាន់រវាងអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ដោយប្រើប្រាស់យន្តការដែលមានស្រាប់ ដូចជា វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា គណៈកម្មការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសជាដើម។
- គួរមានការបើកទូលាយ និងទទួលយកនូវការទំនាក់ទំនងជាប្រចាំ និងករណីបន្ទាន់ជាមួយ អង្គការ-សង្គមស៊ីវិលដែលគំនិត និងទស្សនៈរបស់ខ្លួនត្រូវបានស្តាប់ និងទទួលយក
- ជួយអង្គការសង្គមស៊ីវិលដើម្បីធានានូវការសហការ និងការគាំទ្រពីអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

បន្ថែមលើសំណើខាងលើនេះ យើងខ្ញុំក៏សូមស្នើដល់ប្រទេសម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍ដ៏ទៃទៀត សូម៖

- ផ្តល់នូវថវិកាគាំទ្រដល់ដំណើរការរយៈពេលវែងដល់អង្គការសង្គមស៊ីវិល
- ផ្តល់នូវថវិកាសំរាប់ដំណើរការរដ្ឋបាលដល់ អង្គការសង្គមស៊ីវិលដោយគាំទ្រដល់ការកសាងសមត្ថភាពសំរាប់ការ ឆ្លើយតបទៅនឹងអ្នកដែលទទួលបានផលប្រយោជន៍
- ផ្តល់មូលនិធិគាំទ្រដល់កម្មវិធីក្នុងការកសាងសមត្ថភាពស្ថាប័ន

រៀបចំដោយ

រួមសហការដោយ

- គោរពអភិបាលកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល និងជៀសវាងការមានឥទ្ធិពលណាមួយទៅលើបេសកកម្ម របស់អង្គការសង្គមស៊ីវិល
- កាត់បន្ថយនូវភាពស្មុគស្មាញពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យសំរាប់ការទទួលបានមូលនិធិ
- បង្កើតនូវមូលនិធិមួយផ្នែកដើម្បីធានាដល់និរន្តរភាពនៃអង្គការមិនមែនរដ្ឋាភិបាលតូចៗ និងអង្គការសហគមន៍ នៅតាមមូលដ្ឋាន
- សំរបសំរួលនូវការចូលរួមរបស់អង្គការសង្គមស៊ីវិលទៅក្នុងដំណើរការអភិវឌ្ឍន៍កម្ពុជាទាំងថ្នាក់ជាតិ និង ថ្នាក់ ក្រោមជាតិ។